កាលពីព្រេងនាយមានបុរសម្នាក់ខ្ចើមក្ដីឡើងចុងត្នោត ហើយយកស្លឹកត្នោតចាក់ស្មុគធ្វើរូបសត្វផ្សេង ៗ ។ ហើយគិតថា "អញលក់ស្មុគទាំងអស់នោះយកប្រាក់ទៅទិញសំលៀកបំពាក់ និងទិញក្របីធ្វើស្រែ ហើយនឹងលោះខ្ញុំប្រើបើកាលណាអញប្រើវាមិនបាន អញនឹងវាយធាក់វា" ថា តែប៉ុណ្ណោះក៏យកជើងធាក់ស្មុគនោះ ធាក់មិនតិចតួចធាក់ទាល់តែភ្លាត់ជើង ធ្លាក់ពីលើចុងត្នោត តែបុរសនោះស្រវាចាប់ចុងត្នោតជាប់ដូចជាគេចងព្យួរតែកតោកនៅនោះ ។ បុរសនោះភ័យណាស់មិនដឹងបើគណនាឡើយ ។

ពេលនោះបុរសម្នាក់ទៀតដែរ ខ្ចើមអាចម៍ជិះនៅតែលើខ្នងដំរី ក៏បរដំរីនោះទៅលុះដល់ក្រោមដើមត្នោត បុរសខ្ចើមក្ដីក្រឡេកឃើញក៏ស្រែកហៅថា "ឱអ្នកជិះដំរីមេត្តាជួយយកអោយខ្ញុំផង" ។ បុរសជិះដំរីក្រឡេកឃើញបុរសខ្ចើមក្ដីតោងធាងត្នោតព្យួរខ្លួននៅនោះ ក៏ឆ្លើយតបទៅវិញថា "មិនដឹងជួយដូចម្ដេចទេ" ។ បុរសនៅលើចុងត្នោតថា "ត្រូវអ្នកបរដំរីមកខាងក្រោមខ្ញុំ ហើយត្រូវឈរទាញជើងខ្ញុំចុះ" ។ បុរសជិះដំរីឮហើយក៏បរដំរីទៅពីក្រោម រួចក្រោកឈរលើខ្នងដំរីលើកដៃប្រវាចាប់ជើងកំពុងតែចាប់ជើង ដំរីនោះវាដូចជាគេទទោកដេញវាៗដើរទៅ ។ បុរសពីរនាក់ក៏ព្យួរតែកតោកនៅនោះ ។ បុរសខាងលើភ័យពេករាកអាចម៍ដាក់ក្បាលបុរសខាងក្រោម ។ បុរសពីរនាក់ភ័យណាស់មិនដឹងធ្វើដូចម្ដេច ។ ក្នុងវេលានោះមានបុរសទំពែកទាំង៤ នាក់ដើររកស៊ីកាត់ក្ដី លុះដើរទៅដល់កន្លែងនោះ បុរសពីរនាក់ដែលតោងធាងត្នោតនោះស្រែកថា "នែលោកទាំង ៤ នាក់ដែលដើរនោះមេត្តាជួយយកអាយុខ្ញុំផង សឹមខ្ញុំទៅនៅជាខ្ញុំបម្រើលោក" ។ បុរសទំពែក ៤នាក់ឮ ងើបមើលទៅឃើញបុរសពីរនាក់នោះ ក៏ជំនុំគ្នាថា "យើងទាំង ៤នាក់ តាំងពីដើររកស៊ីកាត់ក្ដីថ្ងៃណាមិនដែលបានខ្ញុំប្រើសោះ ឥឡូវយើងគិតយកបុរសពីនាក់នេះធ្វើខ្ញុំយើង" គិតដូច្នោះហើយបុរសទាំង៤ នាក់ដើរចូល

ទៅក្រោមដើមត្នោតក៏និយាយថា “ យើងមិនដឹងធ្វើម្តេចទេ ” ។ បុរសពីរនាក់ថា “ ឱលោកអើយ! លោកយកសំពត់នោះចងនឹងកលោកម្នាក់ ១ជ្រុង ហើយឈរទាញអោយតឹងពីក្រោមខ្ញុំៗ នឹងទម្លាក់ខ្លួនខ្ញុំទៅលើសំពត់នោះ” ។ បុរស ៤នាក់ស្តាប់ហើយក៏ធ្វើតាមពាក្យបុរសពីរនាក់ស្រេចហើយ បុរសពីរនាក់ទម្លាក់ខ្លួនមកសំពត់នោះ ។ ឯបុរសទាំងបួនក៏ទង្គិចក្បាលគ្នាស្លាប់អស់ទៅ ។ បុរសពីរនាក់ដឹងថា អ្នកទាំង ៤នាក់ស្លាប់ហើយភ័យណាស់ លុះយប់មានផ្ទះយាយចាស់ម្នាក់ប្តីគាត់មិននៅ ទៅធ្វើចម្ការបុរសពីរនាក់ក៏នាំគ្នាសែងខ្មោចបុរសទំពែកទាំង៤ យកទៅដាក់នៅរានហាលផ្ទះនោះ ហើយនាំគ្នារត់ទៅ ។លុះព្រឹកឡើងយាយចាស់នោះភ្ញាក់ពីដេក ចេញទៅលុបមុខខាងក្រៅឃើញខ្មោចនោះហើយ ភ្ញាក់ព្រើតថា “ យី ខ្មោចអ្វីមកស្លាប់នៅនោះ ? ” ថា ហើយក៏អូសខ្មោចនោះមួយម្តងៗ យកទៅដាក់ក្នុងផ្ទះ ហើយយកខ្មោចនោះមករុំសំពត់យកមកដាក់ខាងក្រៅផ្ទះយំទួញថា ប្តីស្លាប់ ហើយដើរទៅរកអ្នកស្រុកអោយគេជួយយកទៅកប់ អ្នកស្រុកមកជួយយកខ្មោចនោះទៅកប់ ហើយត្រឡប់មកផ្ទះវិញ ។ លុះស្អែកឡើងយាយចាស់ធ្វើដូចមុនទៀតប្រាប់គេថា “ប្តីខ្លួនត្រឡប់មកវិញ” ។ អ្នកស្រុកគេក៏ជួយទៀត លុះខានស្អែកឡើងយាយធ្វើយ៉ាងនេះទៀតទាល់តែគ្រប់ខ្មោចទាំង ៤ ។ អ្នកស្រុកគិតថា “ យើងទៅវាយខ្មោចនេះក្រែងមកទៀតគិតហើយនាំគ្នាទៅចាំនៅផ្លូវដែលយកខ្មោចនោះទៅកប់” ។ លុះព្រលប់ តាប្តីយាយនោះអស់អង្ករត្រឡប់ពីចម្ការ មកយកអង្ករស៊ីលីផ្សាំងមួយផង មកដល់ប្រទះនឹងពួកអ្នកស្រុកដែលគេចាំនោះគេស្រែកថា “កនយើងមកទៀតហើយ ” គេនាំគ្នាដេញវាយ តាស្រែក“ខ្ញុំទេ ខ្ញុំមកពីចម្ការ ។ គេថា អាឯងស្លាប់ទៅហើយមកវិញ ៤-៥ដងអោយតែគេពិបាក ”គេក៏វាយតានោះទាល់តែស្លាប់ទៅ ។

**ខ្ចីមអាចម៍ឡើងជិះដីរខ្ចីមត្អីឡើងចុងត្នោត**